# បញ្ហានានាជុំវិញការលែងលះ (សេចក្តីពន្យល់ត្រួសៗអំពីច្បាប់ជប៉ុន)

Prof. Akanishi Yoshifumi

## 1 ស្ថាប័នចាត់ចែងពាក់ព័ន្ធនឹងបញ្ហាគ្រួសារ រួមទាំងការលែងលះ

វិវាទស្តីពីបញ្ហាគ្រួសារ ច្រើនតែជាវិវាទដែលមានពាក់ព័ន្ធរួមទាំងកូន ឬឪពុកម្តាយ ហើយដែលមិនអាចចាត់ការទៅតាមគោលការណ៍នៃកិច្ចសន្យាបាន។ ហេតុនេះហើយ ពីឆ្នាំ២០០៣មក ជប៉ុនបានបង្កើតតុលាការគ្រួសារសម្រាប់ចាត់ការផ្តាច់មុខក្នុងការជំនុំជម្រះលើកទី១ នូវរឿងក្តីលែងលះ។ ស្តីពីការជំនុំជម្រះនេះ ដើម្បីផ្តល់ឱកាសព្រមព្រៀងតាមរយៈការពិគ្រោះរវាងភាគី មុននឹងធ្វើការជំនុំជម្រះ តុលាការច្រើនតែយកគោលការណ៍ធ្វើសន្ធានកម្មមុនជំនុំជម្រះ ហើយពាក់ព័ន្ធនឹងរឿងលែងលះក៏ដូចគ្នាដែរ។

ស្តីពីរឿងក្តីលែងលះ ត្រូវអនុវត្តក្រមនីតិវិធីស្តីពីឋានៈបុគ្គល។ ច្បាប់នេះខុសពីក្រមនីតិវិធីរដ្ឋប្បវេណី គឺមានបញ្ញត្តិដែលអនុញ្ញាតឱ្យតុលាការធ្វើការពិចារណាអំពីអង្គហេតុដែលភាគីមិនបានអះអាង ឬធ្វើការបញ្ជាក់ភស្តុតាងដោយឆន្ទានុសិទ្ធិរបស់ខ្លួនបាន។

ស្តីពីបញ្ហាគតិយុត្តដែលកើតមានឡើងពាក់ព័ន្ធនឹងការលែងលះ ពាក់ព័ន្ធនឹងប្តីប្រពន្ធ មានបញ្ហាបែងចែកទ្រព្យសម្បត្តិ បញ្ហាសំណងជម្ងឺចិត្ត បញ្ហាចំណាយលើអាពាហ៍ពិពាហ៍ក្នុងអំឡុងពេលរស់នៅបែកគ្នា រីឯបញ្ហាពាក់ព័ន្ធនឹងកូនវិញ មានបញ្ហាអាហារកិច្ច បញ្ហាជួបប្រាស្រ័យទាក់ទង បញ្ហាប្រគល់កូន ជាដើម។

## 2 ការបង្កើតទំនាក់ទំនងអាពាហ៍ពិពាហ៍ និង អានុភាព (ជាបុរេល័ក្ខខ័ណ្ឌ)

### (1) បុរេល័ក្ខខ័ណ្ឌ

អាចបង្កើតបានតែក្នុងករណីដែលមានការព្រមព្រៀងពីភេទទាំងពីរប៉ុណ្ណោះ (រដ្ឋធម្មនុញ្ញ មាត្រា២៤)។ នេះអាចគិតថា ជាកិច្ចសន្យាមួយប្រភេទបានដែរ។ ចំណុចនេះ នៅក្នុងក្រមរដ្ឋប្បវេណីកម្ពុជា មាត្រា ៩៤៤ ចែងថា ល័ក្ខខ័ណ្ឌនៃការបង្កើតកំជាប់ពាក្យ គឺការព្រមព្រៀង និង ការធ្វើពិធីកំជាប់ពាក្យ។

ប្តីប្រពន្ធមានសិទ្ធិស្មើគ្នា (រដ្ឋធម្មនុញ្ញ មាត្រា ២៤)។ គោលការណ៍ឯកពន្ធភាព។

### (2) ល័ក្ខខ័ណ្ឌនៃការបង្កើតចំណងអាពាហ៍ពិពាហ៍

ដោយសារតែគេទាមទារឱ្យសង្គមដឹងយ៉ាងទូលំទូលាយអំពីអាពាហ៍ពិពាហ៍ ហេតុនេះហើយគេបានជ្រើសរើសយកគោលការណ៍អាពាហ៍ពិពាហ៍តាមច្បាប់ ដែលបង្កើតតាមនីតិវិធីកំណត់ដោយច្បាប់។ នៅជប៉ុន ដើម្បីបង្កើតចំណងអាពាហ៍ពិពាហ៍ ត្រូវជូនដំណឹងអំពីអាពាហ៍ពិពាហ៍ (ជូនដំណឹងទៅកន្លែងទទួលបន្ទុកអំពីអត្រានុកូលដ្ឋាន) ជូនអ្នកទទួលបន្ទុក

កិច្ចការអត្រានុកូលដ្ឋាននៅសាលាសង្កាត់ស្រុកឃុំភូមិ ជាដើម (គោលការណ៍អាពាហ៍ពិពាហ៍តាមការជូនដំណឹង)។ មាត្រា ៧៣៩។

នៅកម្ពុជា យោងតាមមាត្រា ៩៥៥ កថាខ័ណ្ឌទី១ចែងថា "អាពាហ៍ពិពាហ៍នឹងមានអានុភាពដោយការដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍ ការជូនដំណឹងជាសាធារណៈ ការចុះកិច្ចសន្យាអាពាហ៍ពិពាហ៍ និង ការចុះបញ្ជីនៅចំពោះមុខមន្ត្រីអត្រានុកូលដ្ឋាន ។" គឺមិនមែនត្រឹមតែជូនដំណឹងទេ ថែមទាំងត្រូវបង្កើតកិច្ចសន្យាអាពាហ៍ពិពាហ៍ និង ចុះបញ្ជីអត្រានុកូលដ្ឋានផង។

(3) ល័ក្ខខ័ណ្ឌអានុភាពនៃអាពាហ៍ពិពាហ៍

ត្រូវមានឆន្ទៈរៀបអាពាហ៍ពិពាហ៍ (ឆន្ទៈបង្កើតទំនាក់ទំនងដែលគេទទួលស្គាល់ថាជាប្តីប្រពន្ធក្នុងជីវភាពរស់នៅក្នុងសង្គម), ពុំមានមូលហេតុដែលជាឧបស័គនៃអាពាហ៍ពិពាហ៍ (① អាយុ បុរស ១៨ឆ្នាំ, នារី ១៦ឆ្នាំ, ②ការហាមអាពាហ៍ពិពាហ៍ជាន់គ្នា, ③ការហាមអាពាហ៍ពិពាហ៍រវាងសាច់ញាតិជិតៗ, ④អំឡុងពេលហាមអាពាហ៍ពិពាហ៍ថ្មី)។ ក្នុងក្រមរដ្ឋប្បវេណីកម្ពុជា ក៏មានបញ្ញត្តិចែងដូចគ្នាដែរ។

(ឧទាហរណ៍)

បុរស A និងនារី Bបានស្រឡាញ់គ្នា ហើយនាង B មានផ្ទៃពោះ។ បុរសA ចង់ទៅភ្ជាប់ពាក្យអាពាហ៍ពិពាហ៍នឹងនារី C ហើយឈប់ទាក់ទងនឹងនារី B។ នារី B ចង់បញ្ចូលកូនរបស់ខ្លួនទៅក្នុងបញ្ជីអត្រានុកូលដ្ឋានរវាង A និងB ហើយបន្ទាប់មកទើបសុំលែងលះ។ A ក៏យល់ព្រម ហើយក៏ជូនដំណឹងអំពីអាពាហ៍ពិពាហ៍នេះទៅសាលាស្រុក។ តែក្រោយមក នាង B មិនយល់ព្រមលែងលះ តើអាពាហ៍ពិពាហ៍រ វាង A និងB នេះមានអានុភាព ឬទេ ?

(4) អានុភាពសំខាន់ៗនៃអាពាហ៍ពិពាហ៍

ក. ប្តីប្រពន្ធ ត្រកូលដូចគ្នា

នៅជប៉ុន មានគេទិទានដែរ។ តាមប្រជាមតិ ប្តីប្រពន្ធដែលមានអាយុក្រោម៥០ឆ្នាំ ជាងពាក់កណ្តាលយល់ព្រមអំពីមតិប្តីប្រពន្ធត្រកូលផ្សេងគ្នា។ រីឯនៅក្នុងក្រមរដ្ឋប្បវេណីកម្ពុជា មាត្រា៩៦៥វិញ ប្តីប្រពន្ធអាចប្រើត្រកូលរបស់ខ្លួនដែលមាន មុនអាពាហ៍ពិពាហ៍។

ខ. កាតព្វកិច្ចរួមរស់ជាមួយគ្នា សហការ និងជួយសង្គ្រោះគ្នាទៅវិញទៅមក

ក្រមរដ្ឋប្បវេណីកម្ពុជា មាត្រា ៩៦៦ មានចែងដូចគ្នាដែរ។ នៅជប៉ុន ទោះបីជាមានសេចក្តីសម្រេចឱ្យរួមរស់ជាមួយគ្នាក៏ដោយ ក៏គេមិនទទួលស្គាល់នូវការអនុវត្តដោយបង្ខំ រួមទាំងការបង្ខំដោយប្រយោលដែរ។ ដីការសម្រេចរបស់តុលាការកំពូលនៅថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ ១៩៣០។

គ. កាតព្វកិច្ចមិនត្រូវផិត

នៅក្នុងច្បាប់ គ្មានបញ្ញត្តិណាមួយចែងទេ តែតុលាការទទួលស្គាល់នូវបញ្ហានេះ ហើយប្រសិនជាប្ដី ឬប្រពន្ធផិត តុលាការទទួលស្គាល់នូវសំណងជម្ងឺចិត្តចំពោះភាគីម្ខាងទៀត។ ក៏ប៉ុន្តែក្នុងករណីដែលអាពាហ៍ពិពាហ៍នោះបែកបាក់ហើយ តុលាការមិនទទួលស្គាល់នូវការទទួលខុសត្រូវចំពោះអំពើផិតទេ។ សាលដីការបស់តុលាការកំពូល នៅថ្ងៃទី២៦ មីនា ១៩៩៦។

ឃ. របបទ្រព្យសម្បត្តិប្ដីប្រពន្ធ

គេអាចបង្កើតកិច្ចសន្យាស្ដីពីទ្រព្យសម្បត្តិរវាងប្ដីប្រពន្ធ ហើយបើសិនជាពុំបានបង្កើតកិច្ចសន្យានេះទេ ត្រូវអនុវត្តតាមរបបទ្រព្យសម្បត្តិដែលច្បាប់បានកំណត់។ កិច្ចសន្យាទ្រព្យសម្បត្តិត្រូវចុះបញ្ជីមុនពេលអាពាហ៍ពិពាហ៍ ម្យ៉ាងទៀត គេមិនអាចប្ដូរក្រោយអាពាហ៍ពិពាហ៍ជាដាច់ខាត ហេតុនេះហើយ នៅជប៉ុន គេមិនសូវប្រើរបបនេះទេ។ មាត្រា៧៥៥~មាត្រា៧៥៨។

របបទ្រព្យសម្បត្តិដែលច្បាប់កំណត់ គឺជារបបទ្រព្យសម្បត្តិដោយឡែករបស់ប្ដីប្រពន្ធ (មាត្រា762)។ មានន័យថា ទ្រព្យសម្បត្តិដែលប្ដី ឬប្រពន្ធ មានពីមុនពេលរៀបអាពាហ៍ពិពាហ៍ និងទ្រព្យសម្បត្តិដែលបានដោយឈ្មោះសាមីខ្លួនក្នុងអំឡុងពេលអាពាហ៍ពិពាហ៍ គឺជាទ្រព្យសម្បត្តិដោយឡែករបស់អ្នកនោះ។ ចំពោះបញ្ហានេះ មានគេទិទានថា របបនេះមិនបានគិតដល់ការងាររបស់ស្ត្រីដែលជាមេផ្ទះធ្វើការតែក្នុងផ្ទះ។

រីឯកម្ពុជាវិញ បើសិនជាមិនបានបង្កើតកិច្ចសន្យាអំពីទ្រព្យសម្បត្តិប្ដីប្រពន្ធទេ ត្រូវអនុវត្តតាមរបបទ្រព្យសម្បត្តិដែលច្បាប់កំណត់ដែរ (ក្រមរដ្ឋប្បវេណីកម្ពុជា ពីមាត្រា969ទៅ) ហើយទ្រព្យសម្បត្តិដោយឡែក មានតែទ្រព្យសម្បត្តិដែលបានលទ្ធកម្មតាមរយៈប្រទានកម្ម សន្តតិកម្ម ឬអច្ច័យទាន ព្រមទាំងប្រាក់ដែលបានមកពីការចាត់ចែងទ្រព្យសម្បត្តិទាំងនេះ (មាត្រា972)។ ដូច្នេះក្រៅពីនេះ ត្រូវចាត់ទុកថាជាទ្រព្យសម្បត្តិរួម (មាត្រា 973)។ លើសពីនេះ បើសិនជាចង់ចាត់ចែងទ្រព្យសម្បត្តិរួម ត្រូវមានការព្រមព្រៀងពីភាគីទាំងសងខាង ហើយក្នុងករណីដែលបានចាត់ចែងទ្រព្យសម្បត្តិរួមនេះដោយពុំមានការព្រមព្រៀងពីភាគីម្ខាងទៀតទេ អាចលុបចោលនូវការចាត់ចែងនេះបាន (មាត្រា976)។ លើសពីនេះ មានបញ្ញត្តិចែងថា ប្ដីប្រពន្ធម្ខាងអាចអាស្រ័យនៅលើអចលនវត្ថុដែលជាទ្រព្យសម្បត្តិដោយឡែករបស់សហព័ទ្ធម្ខាងទៀត ហើយដែលត្រូវបានប្រើសម្រាប់ការអាស្រ័យនៅរបស់គ្រួសារបាន (មាត្រា977)។

(ឧទាហរណ៍)

“ A និង B ជាប្ដីប្រពន្ធ ហើយគាត់បានរៀបអាពាហ៍ពិពាហ៍ ហើយរស់នៅជាមួយគ្នា ៣០ឆ្នាំមកហើយ។ ប្ដីធ្វើការនៅក្រុមហ៊ុន ហើយគាត់ធ្វើការត្រឹមត្រូវរយៈពេល ៣០ឆ្នាំហើយៗបានទិញដីនិងផ្ទះ

ដោយដាក់ឈ្មោះប្ដី។ ប្រពន្ធជាមេផ្ទះ មិនទៅធ្វើការទេ ហើយគាត់ទទួលខុសត្រូវធ្វើការងារផ្ទះ ដូចជាដាំស្ល បោកគក់ ជាដើម ហើយចិញ្ចឹមកូន២នាក់។ B និយាយថា A ធ្វើការនៅក្រុមហ៊ុនបានប្រាក់ខែយកមកទិញដីនិងផ្ទះបាន ក៏ដោយសារតែ B ធ្វើការងារផ្ទះ និងបីបាច់រក្សាកូនដែរ ហើយគាត់ទាមទារឱ្យ A ចុះបញ្ជីកម្មសិទ្ធិដីនិងផ្ទះ 1/2 ដែលជាចំណែករបស់គាត់ មកឱ្យគាត់ "។

នៅជប៉ុន ក្នុងករណីដែលប្រពន្ធជាស្ត្រីមេផ្ទះ ហើយបើសិនជាបានលទ្ធកម្មអចលនវត្ថុដោយមានឈ្មោះប្ដីជាម្ចាស់កម្មសិទ្ធិ ក្នុងអំឡុងពេលអាពាហ៍ពិពាហ៍ ជាគោលការណ៍ ប្រពន្ធមិនអាចអះអាងអំពីសិទ្ធិរបស់ខ្លួនបានទេ ។ នេះគឺជាបញ្ហាដែលគេបានលើកឡើង។ តើត្រូវធ្វើការវាយតម្លៃយ៉ាងដូចម្ដេចចំពោះការជួយប្ដីតាមរយៈការងារមេផ្ទះនេះ។ ស្ដីពីចំណុចនេះ តាមយុត្តិសាស្ត្រតុលាការ គេមានគំនិតទទួលស្គាល់ច្រើន ដោយគណនាទៅតាមចំណែកនៃវិភាគទាននោះ នៅពេលបែងចែកទ្រព្យសម្បត្តិ។

3 ស្ដីពីការលែងលះ

(1) ប្រភេទនៃការលែងលះ

ការលែងលះតាមរយៈការពិគ្រោះ (មាត្រា 763) មានច្រើន។ ហើយល័ក្ខខ័ណ្ឌ គឺ ត្រូវកំណត់សិទ្ធិអំណាចមេបា (មាត្រា 819 កថាខ័ណ្ឌទី1)។ នៅជប៉ុន ម្ដាយមានសិទ្ធិអំណាចមេបាប្រហែល 80%។ ក្នុងមាត្រា 766 ពេលពិគ្រោះអំពីការលែងលះគ្នា ត្រូវកំណត់អំពីអ្នកបីបាច់រក្សា ការប្រាស្រ័យទាក់ទង និង អាហារកិច្ច។ ក៏ប៉ុន្តែ ជាក់ស្ដែង មានភាគតិចណាស់ដែលបានកំណត់អំពីការប្រាស្រ័យទាក់ទង និង អាហារកាតព្វកិច្ច។

ក្រៅពីនេះ មានការលែងលះតាមផ្លូវបណ្ដឹង ការលែងលះតាមសន្ធានកម្ម ការលែងលះតាមការសម្រេចរបស់តុលាការ ការលែងលះតាមការសះជា។

នៅជប៉ុន 90%នៃការលែងលះ គឺជាការលែងលះតាមការពិគ្រោះ ហើយការលែងលះតាមសន្ធានកម្មរបស់តុលាការគ្រួសារមានខ្ទង់ 10 %។ ការលែងលះតាមបណ្ដឹង មានប្រហែល 1%។ ក្នុងសហគមន៍អន្តរជាតិ មិនសូវមានប្រទេសដែលជ្រើសរើសយករបបលែងលះតាមការពិគ្រោះទេ។ នៅក្នុងក្រមរដ្ឋប្បវេណីកម្ពុជា មាត្រា 979 មានចែងអំពីការលែងលះតាមការពិគ្រោះដែរ។ ក៏ប៉ុន្តែទោះជាបានព្រមព្រៀងក៏ដោយ ក៏មិនមែនមានអានុភាពលែងលះគ្នាភ្លាមៗទេ គឺត្រូវដាក់ពាក្យសុំលែងលះជូនតុលាការ។ តុលាការនឹងធ្វើការបញ្ជាក់អំពីទឹកចិត្តនៃការលែងលះរបស់ភាគី ទើបទទួលស្គាល់នូវការលែងលះនេះ។

(2) មូលហេតុនៃការលែងលះតាមផ្លូវតុលាការ

ក្រមរដ្ឋប្បវេណីជប៉ុន មាត្រា 770 ក្រមរដ្ឋប្បវេណីកម្ពុជា មាត្រា 978

| | |
|---|---|
| ① អំពើផិត | ① |
| ② ការបោះបង់ចោលដោយគំនិតអាក្រក់ | ② ○ ការបោះបង់ចោលដោយគ្មានមូលហេតុត្រឹមត្រូវ |
| ③ មិនដឹងថា ស្លាប់ ឬរស់អស់រយៈពេលជាង3ឆ្នាំ | ③ →មិនដឹងថាស្លាប់ ឬរស់អស់រយៈពេលជាង1ឆ្នាំ |
| ④ ជម្ងឺផ្លូវចិត្តដែលគ្មានសង្ឃឹមថានឹងជា | × |
| ⑤ មូលហេតុធ្ងន់ធ្ងរផ្សេងទៀត ដែលមានការលំបាកនឹងបន្តអាពាហ៍ពិពាហ៍ | ⑤ ○(ទំនាក់ទំនងអាពាហ៍ពិពាហ៍ត្រូវបានបែកបាក់ ហើយគ្មានសង្ឃឹមថានឹងអាចបដិទានឡើងវិញបាន) |
| ⑥ × | ④ សហព័ទ្ធបានរស់នៅបែកគ្នាជាបន្តបន្ទាប់ អស់រយៈពេលជាង១ឆ្នាំ ផ្ទុយនឹងគោលបំណងនៃអាពាហ៍ពិពាហ៍ |

① អំពើផិត

គឺមានន័យថា ទំនាក់ទំនងផ្លូវភេទ។

មានការពិបាកនឹងបញ្ជាក់ភស្តុតាង។

(ឧទាហរណ៍)

ប្តីបានទទួលស្គាល់ថា គាត់បានទៅសណ្ឋាគារនឹងនារីម្នាក់ តែគាត់អះអាងថា នៅក្នុងសណ្ឋាគារ នារីនោះពិគ្រោះអំពីការងារតែប៉ុណ្ណោះ។

ម្យ៉ាងទៀត ប្តីជាអ្នកគ្រប់គ្រងការិយាល័យគណនេយ្យករខ្លួនឯង ហើយនៅពេលបុគ្គលិកទៅផ្ទះទាំងអស់គ្នា គាត់នៅក្នុងការិយាល័យតែឯង ហើយពេលនោះ នារីនោះបានចូលការិយាល័យគាត់។ ប្រហែលមួយម៉ោងក្រោយ គាត់ចេញទាំងពីរនាក់។ គាត់និយាយថា នារីនោះមកពិគ្រោះអំពីបញ្ហាការងារ។ ក្នុងអំឡុងពេលដែលនារីនោះមកនៅក្នុងការិយាល័យ មិនដឹងជាគាត់បិទភ្លើងបន្ទប់ឬទេ ពីព្រោះមើលពីក្រៅមិនដឹងច្បាស់។

② ការបោះបង់ចោលដោយគំនិតអាក្រក់ ការធ្វើផ្ទុយនឹងកាតព្វកិច្ចរួមរស់ជាមួយគ្នា សហការនិងជួយសង្គ្រោះគ្នាទៅវិញទៅមក ដោយគ្មានមូលហេតុត្រឹមត្រូវ។

③ មិនដឹងស្លាប់ ឬរស់រយៈពេលជាង៣ឆ្នាំ

④ មានជម្ងឺផ្លូវចិត្តធ្ងន់ធ្ងរដែលមិនសង្ឃឹមថានឹងអាចបដិទានឡើងវិញបាន

ក្នុងករណីដែលមិនបានចាត់វិធានការជាក់ស្តែងស្តីពីការព្យាបាលតទៅមុខនៃអ្នកជម្ងឺ ឬស្តីពីជីវភាពរស់នៅ ហើយដែលអាចមានស្ថានភាពស្រួលបួលវិញទេ តុលាការកំពូលមិនអនុញ្ញាតការលែងលះទេ (សាលដីកានៅថ្ងៃទី25 ខែកក្កដា ឆ្នាំ1958)។ នៅក្នុងក្រមរដ្ឋប្បវេណី

កម្ពុជា ពុំមានបញ្ញត្តិណាមួយចែងដូចនេះទេ ក៏ប៉ុន្តែប្រហែលជាចំណុច ង. ត្រូវគ្នានឹងចំណុចនេះក៏មិនដឹង។ ក៏ប៉ុន្តែ នៅពេលដែលសហព័ទ្ធនឹងជួបការលំបាកធ្ងន់ធ្ងរ ឬការទាមទារលែងលះនោះផ្ទុយនឹងគោលការណ៍នៃភាពសុចរិត ប្រហែលជាតុលាការនឹងច្រានចោលដោយយោងតាមកថាខ័ណ្ឌទី២ និងទី៣។

⑤ មូលហេតុធ្ងន់ធ្ងរផ្សេងទៀត ដែលមានការលំបាកនឹងបន្តអាពាហ៍ពិពាហ៍

នៅក្នុងក្រមរដ្ឋប្បវេណីជប៉ុន បើសិនជាមិនអនុវត្តតាមមាត្រា 770 កថាខ័ណ្ឌទី2 ទេ (ច្រានចោលនូវការទាមទារដោយពិចារណាដល់គ្រប់ស្ថានភាពផ្សេងៗ)។ ក្នុងក្រមរដ្ឋប្បវេណីកម្ពុជា តុលាការអាចច្រានចោលដោយឆន្ទានុសិទ្ធិបាន ក្នុងករណីដូចដែលមានចែងក្នុងមាត្រា 978 កថាខ័ណ្ឌទី3។

ករណីដែលត្រូវនឹងល័ក្ខខ័ណ្ឌនេះ មានដូចជា អំពើហិង្សា អំពើធ្វើបាប ការប្រមាថមើលងាយធ្ងន់ធ្ងរ អំពើឧក្រិដ្ឋកម្ម ទម្លាប់ចាយវាយផ្តេសផ្តាស់ខ្ជះខ្ជាយខ្លាំង គ្មានចិត្តធ្វើការងារ (លេងតែល្បែងស៊ីសង ជាដើម) មានបញ្ហាក្នុងការរួមភេទ ទស្សនៈជីវិតមិនត្រូវគ្នា មិនត្រូវនឹងសាច់ញាតិខាងសហព័ទ្ធ ធ្វើសកម្មភាពសាសនាខ្លាំងជ្រុល ជាដើម។ ក្នុងករណីដែលមានមូលហេតុខាងលើនេះ ហើយបន្ថែមនឹងការរស់នៅបែកគ្នា ២ ឬ៣ឆ្នាំ តុលាការអាចងាយស្រួលនឹងទទួលស្គាល់ថា មានមូលហេតុធ្ងន់ធ្ងរបាន។ នៅក្នុងច្បាប់កម្ពុជា មានបញ្ញត្តិចែងអំពីល័ក្ខខ័ណ្ឌច្បាស់លាស់ជាងច្បាប់ជប៉ុន ក៏ប៉ុន្តែ ជាសារធាតុ ប្រហែលជាពុំមានអ្វីខុសពីច្បាប់ជប៉ុនទេ។ ជាពិសេស ការអនុវត្តជាក់ស្តែង ត្រូវពិចារណាតាមស្ថានភាពនៃប្រទេសនីមួយៗ។

(ឧទាហរណ៍)

" ប្តីជាអ្នកគ្រប់គ្រងហាងលក់រាយ ហើយគាត់រកស៊ីបានកាក់កប រហូតដល់មានហាងបីហើយ។ ប្រពន្ធគាត់ជាមេផ្ទះមិនធ្វើការក្រៅទេ ហើយគាត់រៀបអាពាហ៍ពិពាហ៍បាន៣០ឆ្នាំហើយ រីឯកូនគាត់ក៏ចេញផុតពីបន្ទុករបស់គាត់ ឯករាជ្យពីគាត់ហើយ។ ប្តីជាមនុស្សកំណាញ់ គាត់រអ៊ូរទាំកំប៉ិកកំប៉ុកពាក់ព័ន្ធនឹងចំណាយក្នុងគ្រួសារចំពោះប្រពន្ធគាត់ ហើយគាត់មិនប្រគល់ប្រាក់ឱ្យប្រពន្ធកាន់កាប់សម្រាប់ចំណាយក្នុងជីវភាពរស់នៅប្រចាំថ្ងៃទេ គឺគាត់ដាក់ធនាគារគ្រប់គ្រងខ្លួនឯងទាំងអស់។ លើសពីនេះ ស្តីពីម៉ោងពេលក្រោកពីដំណេក ឬម៉ោងពេលត្រឡប់មកផ្ទះវិញ ឬស្តីពីការសិក្សារបស់កូន ការចូលសាលាជាដើម ក៏គាត់បង្គាប់ច្រើនដែរ។ នៅក្នុងផ្ទះ គាត់ធ្វើអ្វីៗស្រេចតែចិត្តគាត់ មិនឱ្យប្រពន្ធគាត់និយាយអ្វីទាំងអស់។ ប្រពន្ធគាត់ធ្វើតាមគាត់តែខាងក្រៅទេ ក្នុងចិត្តគាត់ទើសចិត្តខ្លាំងណាស់។ ពេលដែលកូនរួចផុតពីបន្ទុកហើយ គាត់មានអារម្មណ៍ស្អប់ប្តីគាត់កាន់តែខ្លាំង ហើយ

គាត់រស់នៅក្នុងបន្ទប់ផ្សេងពីប្តីគាត់បានប្រហែលកន្លះឆ្នាំ ហើយមួយឆ្នាំមុន គាត់ក៏ចេញទៅរស់នៅខាងក្រៅ បែកពីប្តីគាត់ទៅ។ ក្នុងករណីបែបនេះ តើអាចទទួលស្គាល់នូវការទាមទារសុំលែងលះពីប្រពន្ធបានឬទេ ?"

ក្នុងច្បាប់ជប៉ុនក៏ដូចគ្នាដែរ គេបានជ្រើសរើសយកគោលការណ៍នៃការបែកបាក់។ ស្តីពីការទទួលស្គាល់ថា បានបែកបាក់ តើត្រូវគិតយ៉ាងណាដែរចំពោះកត្តាអញ្ញថាភាព (subjective) (ការបាត់បង់ឆន្ទៈបន្តអាពាហ៍ពិពាហ៍) និងកត្តាវត្ថុវិស័យ (objective) (មានការពិបាកនឹងធ្វើបដិទាននូវជីវភាពអាពាហ៍ពិពាហ៍និងរួមរស់ជាមួយគ្នា? ករណីដែលមានជាក់ស្តែងនៅតុលាការ ភាគច្រើនគឺជាករណីដែលមានការពិបាកនឹងវិនិច្ឆ័យ។ អំឡុងពេលរស់នៅបែកគ្នា គឺជាកត្តាសំខាន់ដែលអាចធ្វើការទទួលស្គាល់ដោយវត្ថុវិស័យ។

(3) ការទាមទារសុំលែងលះពីសហព័ទ្ធដែលមានការទទួលខុសត្រូវ (សហព័ទ្ធដែលមានការទទួលខុសត្រូវនូវការរស់នៅបែកគ្នា) (មាននិន្នាការខ្លាំងទៅគោលការណ៍បែកបាក់)

ពីមុនៗ ស្តីពីករណីដែលប្តីបានផិត ហើយបានរស់នៅបែកគ្នាច្រើនឆ្នាំ តុលាការកំពូលមិនអនុញ្ញាតឱ្យលែងលះចំពោះស្ត្រីដែលពុំមានការទទួលខុសត្រូវទេ។ ក៏ប៉ុន្តែ នៅថ្ងៃទី2 ខែកញ្ញា ឆ្នាំ 1987 តុលាការកំពូលបានប្តូរយុត្តិសាស្ត្រវិញ គឺក្នុងករណីដែលអំឡុងពេលរស់នៅបែកគ្នាមានរយៈពេលវែង ហើយគ្មានកូនតូចៗនៅក្នុងបន្ទុក ព្រមទាំងមិនមានស្ថានភាពផ្ទុយនឹងយុត្តិធម៌ក្នុងសង្គមទេ តុលាការកំពូលទទួលស្គាល់នូវការទាមទារសុំលែងលះពីសហព័ទ្ធដែលមានការទទួលខុសត្រូវក្នុងការបែកបាក់នេះ។ ម្យ៉ាងទៀត សេចក្តីព្រាងនៃវិសោធនកម្មក្រមរដ្ឋប្បវេណីរបស់គណកម្មការនីតិកម្ម (ឆ្នាំ1996) អំឡុងពេលរស់នៅបែកគ្នាពី៥ឆ្នាំឡើងទៅ គឺជាមូលហេតុនៃការលែងលះគ្នា។ នៅក្នុងយុត្តិសាស្ត្រតុលាការថ្នាក់ទាប មានករណីខ្លះដែលតុលាការទទួលស្គាល់នូវការសុំលែងលះពីសហព័ទ្ធដែលមានការទទួលខុសត្រូវ។ រីឯក្រមរដ្ឋប្បវេណីកម្ពុជាវិញ គេចែងថា "បើសហព័ទ្ធបានរស់នៅបែកគ្នាជាបន្តបន្ទាប់ អស់រយៈពេលជាង ១ឆ្នាំ ផ្ទុយនឹងគោលបំណងនៃអាពាហ៍ពិពាហ៍" តែមិនដឹងថា តើត្រូវអនុវត្តចំពោះករណីដែលមានការទាមទារសុំលែងលះពីសហព័ទ្ធដែលមានការទទួលខុសត្រូវ ដែរឬទេ?

3 អានុភាពនៃការលែងលះ

(1) តាវកាលិកនៃការលែងលះ

ក. សេចក្តីពន្យល់គ្រួសៗអំពីរបបបែងចែកទ្រព្យសម្បត្តិ (មាត្រា768)

នេះគឺជារបបមួយដែលពិចារណាអំពីជំនួយពីសំណាក់ប្រពន្ធ ដោយឈរលើមូលដ្ឋាននៃរបបទ្រព្យសម្បត្តិប្តីប្រពន្ធដោយឡែក។

ខ្លឹមសារនៃរបបនេះមានបីចំណុចគឺ ①ការទូទាត់ទ្រព្យសម្បត្តិរបស់ប្តីប្រពន្ធ, ②អាហារ

កាតព្វកិច្ចក្រោយពេលលែងលះ, ③សំណងនៃការខូចខាត។

ខ. ការទូទាត់

ទ្រព្យសម្បត្តិដែលជាកម្មវត្ថុនៃការទូទាត់ គឺជាទ្រព្យសម្បត្តិដែលបានមកពីសហប្រតិបត្តិការរបស់ប្តីនិងប្រពន្ធ ហើយមិនពាក់ព័ន្ធនឹងឈ្មោះកម្មសិទ្ធិករទេ។

ត្រូវទូទាត់ទៅតាមទំហំនៃវិភាគទានរបស់សហព័ទ្ធ។

ត្រូវកាត់បន្ថយបំណុលដែលកើតមានឡើងក្នុងជីវភាពរស់នៅរួមគ្នា ពីទ្រព្យសម្បត្តិ។ ឧទាហរណ៍ ប្រាក់កម្ចីសម្រាប់ទិញផ្ទះរស់នៅរបស់គ្រួសារ ជាដើម។ ក្នុងករណីដែលចំនួនប្រាក់កម្ចីនៅមានច្រើនជាងតម្លៃផ្ទះដែលរស់នៅបែកគ្នា មិនត្រូវយកមកទូទាត់ទេ ក៏ប៉ុន្តែនៅពេលធ្វើសន្ទានកម្ម ជួនកាលអាចទទួលស្គាល់នូវសិទ្ធិខ្ចីប្រើដើម្បីធានានៅកន្លែងរស់នៅរបស់ប្រពន្ធកូនក៏មានដែរ។ ម្យ៉ាងទៀត នៅក្នុងការជំនុំជម្រះ ក៏អាចទាញលទ្ធផលដូចគ្នាដែរ ដោយពិចារណាអំពីអាហារកាតព្វកិច្ចពេលលែងលះ។ ស្តីពីចំណុចនេះ នៅកម្ពុជា ឧទាហរណ៍ ក្នុងករណីដែលប្រពន្ធកូនរស់នៅក្នុងផ្ទះដែលជាទ្រព្យសម្បត្តិដោយឡែករបស់ប្តី ក្រោយពេលលែងលះគ្នា គេពិចារណាដល់បញ្ហាលំនៅឋានរបស់ប្រពន្ធកូន (សូមមើលក្រមរដ្ឋប្បវេណី មាត្រា 977) ?

គ. អាហារកាតព្វកិច្ចក្រោយពេលលែងលះ

លើសពីនេះ នៅពេលបែងចែកទ្រព្យសម្បត្តិ ក៏ត្រូវពិចារណាបន្ថែមអំពីអាហារកាតព្វកិច្ចសម្រាប់សហព័ទ្ធដែលមានជីវភាពលំបាកក្រោយពេលលែងលះ។ ស្តីពីហេតុផលវិញ មានទស្សនៈផ្សេងៗគ្នា តែជាពិសេស នេះគឺជាការគិតដល់ស្ត្រីមេផ្ទះដែលជាសហព័ទ្ធក្រីក្រ មិនសូវមានសមត្ថភាពរកចំណូល។ តុលាការពិចារណានូវអាហារកាតព្វកិច្ចសមល្មមឱ្យសហព័ទ្ធអាចរក្សាជីវភាពរស់នៅបាន។

ឃ. សំណងនៃការខូចខាត

ស្តីពីការលែងលះដែលកើតឡើងដោយសារអំពើមានការទទួលខុសត្រូវ តុលាការទទួលស្គាល់នូវសំណងជម្ងឺចិត្តនៅពេលលែងលះ ដែលជាការទទួលខុសត្រូវនៃអំពើអនីត្យានុកូល។

ស្តីពីអំពើផិត ឬអំពើហិង្សា ភាគច្រើន តុលាការទទួលស្គាល់នូវសំណងជម្ងឺចិត្តនេះ។ ក្នុងករណីដែលបានបែងចែកទ្រព្យសម្បត្តិរួចហើយ តែក្នុងទ្រព្យសម្បត្តិដែលបានបែងចែកហើយនោះ ពុំមានផ្នែកនៃសំណងនៃការខូចខាត ឬក៏មានដែរ តែបើធៀបនឹងភាពលំបាកខាងផ្លូវចិត្ត ចំណែកនោះនៅមិនទាន់គ្រប់គ្រាន់ តុលាការកំពូលទទួលស្គាល់នូវសំណងជម្ងឺចិត្តថែមទៀត។ សាលដីកានៅថ្ងៃទី23 ខែកក្កដា ឆ្នាំ1971។

ក៏ប៉ុន្តែ ទឹកប្រាក់នេះមិនជាច្រើនប៉ុន្មានទេ ប្រហែលខ្ទង់ពីរ ទៅប្រាំលានយ៉េនប៉ុណ្ណោះ។

នេះគឺដោយសារតុលាការគិតឃើញថា ការបែងបាក់គ្នា ភាគច្រើន គឺមកពីការទទួលខុសត្រូវទាំងសងខាង ហើយជាគោលការណ៍ ស្តីពីបញ្ហាទ្រព្យសម្បត្តិ តុលាការបានពិចារណាអំពីការលំបាកខាងផ្លូវចិត្តរួចខ្លះហើយ តាមរយៈការទទួលស្គាល់នូវការលែងលះ ដូច្នេះការគិតអំពីសំណងជម្ងឺចិត្ត គឺជាករណីពិសេសទេ។

សំណងជម្ងឺចិត្តដោយសារការលែងលះ មានសំណងជម្ងឺចិត្តលែងលះ និងសំណងជម្ងឺចិត្តដោយសារអំពើដែលមានការទទួលខុសត្រូវ ហើយដែលជាមូលហេតុលែងលះ។ សំណងជម្ងឺចិត្តទាំងពីរនេះផ្សេងគ្នាទេ។ តែនៅពេលជំនុំជម្រះ តុលាការមិនបែងចែកឱ្យដាច់ច្បាស់លាស់ទេ គឺគេវាយតម្លៃជាអំពើអនីត្យានុកូល ដោយពិចារណាទាំងស្រុងនូវដំណើរការពីពេលមានអំពើអនីត្យនុកូលនីមួយៗ រហូតដល់ពេលលែងលះ ហើយគណនាទឹកប្រាក់នៃសំណងជម្ងឺចិត្តនេះ។ កត្តាដែលតុលាការយកមកពិចារណានៅពេលគណនាគឺ ①ភាពមានការទទួលខុសត្រូវ, ②អំឡុងពេលអាពាហ៍ពិពាហ៍, ③ធនធានរបស់ភាគីម្ខាងទៀត។ ជាពិសេស ស្តីពី ① តុលាការពិចារណាអំពីមូលហេតុ និងដំណើរដើមទងនៃការបែកបាក់ ស្ថានភាពនៃជីវភាពអាពាហ៍ពិពាហ៍ អំពើដែលមានការទទួលខុសត្រូវ ចំណែកនៃការទទួលខុសត្រូវ ជាដើម។ ភាគច្រើន មូលហេតុដែលធ្វើឱ្យបែកបាក់គឺមានទាំងសងខាង ដូច្នេះហើយ ត្រូវតែធ្វើការវាយតម្លៃស្តីពីអំពើផិត អំពើហិង្សា ការបោះបង់ចោល ជាដើម ទៅតាមស្តង់ដារច្បាស់លាស់នៃអំពើនោះ ដោយផ្អែកលើភស្តុតាង។

ង. ក្រមរដ្ឋប្បវេណីកម្ពុជា មាត្រា980 បានចែងអំពីការបែងចែកទ្រព្យសម្បត្តិ ។ ក្នុងករណីដែលមិនអាចពិគ្រោះបាន ភាគីម្ខាងៗអាចទទួលនូវទ្រព្យសម្បត្តិដោយឡែករបស់ខ្លួនបាន និងពាក់កណ្តាលនៃទ្រព្យសម្បត្តិរួម។ ក៏ប៉ុន្តែ តុលាការអាចបែងចែកទ្រព្យសម្បត្តិដោយពិចារណាតាមស្ថានភាពផ្សេងៗទាំងអស់ ដូចជាចំណែកនៃវិភាគទានក្នុងការបង្កើតទ្រព្យសម្បត្តិ។ ម្យ៉ាងទៀត ក៏មានបញ្ញត្តិចែងថា កិច្ចការនៅផ្ទះមានតម្លៃស្មើនឹងការងារខាងក្រៅដែរ។ ហេតុនេះហើយ នៅកម្ពុជា ទោះជាស្ត្រីមេផ្ទះក៏ដោយ ភាគច្រើនអាចធ្វើលទ្ធកម្មមួយភាគពីរនៃទ្រព្យសម្បត្តិដែលបានបង្កើតក្រោយអាពាហ៍ពិពាហ៍។

(2) ទំនាក់ទំនងនឹងកូន

ក. ការកំណត់អ្នកមានសិទ្ធិអំណាចមេបា

តុលាការត្រូវធ្វើការវិនិច្ឆ័យដោយពិចារណាទូទៅ រួមទាំងសមត្ថភាពសេដ្ឋកិច្ច ក៏ប៉ុន្តែជាទូទៅ ត្រូវពិចារណាដល់ឆន្ទៈរបស់កូន ដោយយកកូនអាយុខ្ទង់១០ឆ្នាំជាមូលដ្ឋាន។

ក្នុងករណីដែលកូននៅតូច ពីមុនៗ តុលាការច្រើនគិតដល់បញ្ហាម្តាយ តែសព្វថ្ងៃនេះដើម្បីឱ្យមានអព្យាក្រឹតភាព តុលាការច្រើនប្រើទស្សនៈអ្នកបីបាច់រក្សាជាធំ។ នេះមានន័យថា

គឺជាការពិចារណាដល់លទ្ធផលនៃការបីបាច់រក្សា ដូចជាខ្លឹមសារនៃការបីបាច់រក្សា ពេលវេលា ។ល។ នេះគឺដោយសារតែដើម្បីឱ្យកូនមានស្ថេរភាពផ្លូវចិត្ត ត្រូវគិតជាធំអំពីអ្វីៗដែលទាក់ទងនឹងផ្លូវចិត្តរបស់កូន។ ក្រៅពីនេះ ក៏ត្រូវពិចារណាដល់ឥរិយាបថចំពោះការប្រាស្រ័យទាក់ទងនឹងកូនដែរ។ ដូច្នេះ មិនមែនគិតតែអំពីការមិនបំបែកបងប្អូន ឬពីអំពើផិតនៃភាគីម្ខាងជាអាទិ៍ទេ គឺត្រូវគិតដល់ឥទ្ធិពលនៃបញ្ហាទាំងនេះ ទៅលើសុខុមាលភាពរបស់កូន។

ខ. ការកំណត់អ្នកបីបាច់រក្សា

ស្តីពីបញ្ហានេះ ក៏ត្រូវគិតដូចគ្នានឹងបញ្ហាអ្នកមានសិទ្ធិអំណាចមេបាដែរ តែត្រូវគិតជាចំបងថែមទៀតទៅលើកត្តាពាក់ព័ន្ធនឹងចំណងផ្លូវចិត្តរបស់កូន។

គ. ការប្រាស្រ័យទាក់ទង

នេះគឺជាសិទ្ធិនិងកាតព្វកិច្ចរបស់ឪពុកម្តាយផង ហើយក៏ជាសិទ្ធិរបស់កូនផង។

មានពេលខ្លះ តុលាការបានកំណត់អំពីការប្រាស្រ័យទាក់ទងសាកល្បង ឬក៏ប្រើសេវាកម្មរបស់មជ្ឈមណ្ឌលជំនួយរបស់ឯកជនក៏មានដែរ។

បើសិនជាមិនបានកំណត់ឱ្យបានលំអិតអំពីការប្រាស្រ័យទាក់ទងទេ មិនអាចធ្វើការបង្ខំដោយប្រយោលបានឡើយ។

នៅប្រទេសជប៉ុន ពេលថ្មីៗនេះ គេគិតថា ជាគោលការណ៍ គប្បីតែទទួលស្គាល់នូវការប្រាស្រ័យទាក់ទងនេះ តែមានករណីពិសេសដែលមិនទទួលស្គាល់ ដោយពិចារណាទៅលើសុខុមាលភាពរបស់កូន។ ករណីដែលមិនទទួលស្គាល់ការប្រាស្រ័យទាក់ទង មានដូចជាករណីដែលខ្លាចឪពុកម្តាយដែលរស់នៅបែកគ្នា ចាប់កូនទៅ ឬករណីដែលខ្លាចមានអំពើហិង្សា ជាដើម។

ឃ. អាហារកាតព្វកិច្ច

ស្តីពីការលែងលះដោយការព្រមព្រៀង មិនសូវមានករណីដែលត្រូវកំណត់អាហារកាតព្វកិច្ចប៉ុន្មានទេ (ខ្វះ40%) ហើយករណីដែលបានទទួលអាហារកាតព្វកិច្ចជាក់លាក់មានកាន់តែតិចជាងហ្នឹងទៀត។

នេះគឺដោយផ្អែកទៅលើកាតព្វកិច្ចរក្សាជីវភាពរស់នៅ ហើយគេអាចទាមទារនូវស្តង់ដាររស់នៅមួយប្រហែលគ្នានឹងអ្នកមានកាតព្វកិច្ចផ្គត់ផ្គង់អាហារកាតព្វកិច្ចបាន។

ក្រៅពីនេះ ក៏អាចមានករណីដែលតុលាការទទួលស្គាល់នូវអាហារកាតព្វកិច្ចចំពោះកូនដែលជានីតិជន ហើយកំពុងសិក្សានៅមហាវិទ្យាល័យក៏មានដែរ។

បើសិនជាមានការមិនអនុវត្តកាតព្វកិច្ច គេអាចធ្វើការរឹបអូសរហូតដល់តាវកាលិកសម្រាប់អនាគតផងដែរ។ ម្យ៉ាងទៀត ក្នុងករណីដែលធ្វើការរឹបអូសប្រាក់បៀវត្សរ៍ គេអាចរឹបអូសបាន

ដល់ទៅ1/2 ដូច្នេះគឺ ច្រើនជាងករណីនៃសិទ្ធិលើបំណុលធម្មតា (តាមធម្មតា គឺ 1/4)។

(វិធីគណនា)

តុលាការបានកំណត់អំពីស្តង់ដារនៃការគណនា ដោយគិតថា ឪពុកម្តាយមានកាតព្វកិច្ចរក្សាជីវភាពរស់នៅចំពោះកូន ហើយគណនាអំពីចំណាយសម្រាប់ការរស់នៅរបស់កូនតាមសមាមាត្រ ទៅតាមប្រាក់ចំណូលគ្រឹះរបស់ឪពុកនិងម្តាយ (ប្រាក់ចំណូលក្រោយកាត់ពន្ធនិងចំណាយផ្សេងៗដែលចាំបាច់)។

មានមតិខ្លះទិទានថា ការគណនានេះមិនពិចារណាដល់បញ្ហាពិសេសនីមួយៗ ក៏ប៉ុន្តែ ការគណនាបែបនេះមានស្តង់ដារច្បាស់លាស់ ហើយងាយស្រួលធ្វើឱ្យសន្ទានកម្មបានសម្រេច។